# សម្រែកកម្មកររោងចក្រកាត់ដេរ

លំនាំបទ៖ សំលេងឃ្មោះការ

១. សម្រែកកម្មកររោងចក្រកាត់ដេរ ស្រែកប្រាប់អស់ស្រីខ្មែរថាផ្ញើខ្ញុំគេសែនពិបាកក្រៃ
គេតិះគេដៀលដេរស្តីថាស្រីអប្រិយ៍ រស់គ្មានសេរី នៅលើលោកា ។

២. ពួកយើងទាំងអស់គឺជាកម្មករ ខ្ញុំរស់ទាំងត្រដរជីវិតតស៊ូដោយក្តីលំបាក
ទើយហាត់តោកយ៉ាកក៏មិនដែលថា ខ្ញុំប្រឹងធ្វើការ ប្តូរយកដុល្លាដើម្បីជួយម៉ែ ។

បន្ទរ. ចំម្រៀងខ្ញុំច្រៀងរឿងកម្មករពិត មេត្តាអាណិតជួយពិចារណា
ជីវិតកម្មករឈឺចាប់យ៉ាងណា ជួបរឿងខ្លោចផ្សាដោយសារថៅកែគេកេងប្រវ័ញ្ច

៣ ពេលពួកកម្មករជួបរឿងលំបាក តើមានអ្នកណាខ្លះដែលជួយដឹងឮដោះស្រាយបញ្ហា
ឱយុត្តិធម៌អ្នកនៅឯណា ពេលខ្ញុំត្រូវការ ហេតុអ្វីបានជាអ្នកធ្វើព្រងើយ ។